**AUSTRALIAN EMBASSY**
**PHNOM PENH**

# សេចក្តីប្រកាសពត៌មាន

ថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០២១

## អូស្ត្រាលីធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបរិច្ចាគសៀវភៅ

ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ឯកឧត្តម Pablo Kang មានសេចក្តីរីករាយ ដែលបានចូលរួម ជាមួយ ឯកឧត្តម បណ្ឌិត សភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងកម្មវិធី បរិច្ចាគសៀវភៅ ដល់សាលាបឋមសិក្សាព្រះនរោត្តម និងសាលារៀននានាក្នុងប្រទេស ដើម្បីអបអរសប្តាហ៍ សៀវភៅ របស់អូស្ត្រាលី ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២១ ដល់ ២៧ ខែ សីហា។

អូស្ត្រាលី ជាអ្នកគាំទ្រប្រកបដោយមោទនភាព ទៅលើសិទ្ធិទទួលបានការអប់រំសម្រាប់កុមារកម្ពុជា ទាំងអស់ និងបានប្រគល់សៀវភៅ ចំនួន ១ ៣០៨ ក្បាល ដល់សាលាបឋមសិក្សាព្រះនរោត្តម និងសាលា រៀននានាក្នុងប្រទេស ដែលជាអំណោយរបស់ បុគ្គលិកស្ថានទូតអូស្ត្រាលីនិងក្រុមគ្រួសារ សមាជិកសហគមន៍ និងលោក ម៉េង ហៀង អគ្គនាយកក្រុមហ៊ុន ម៉ូនូម៉ែនប៊ុក។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា “ការផ្តោតលើអក្ខរកម្ម និងភាពរីករាយនៃការអាន ជាការសំខាន់ជាងពេលណាៗទាំងអស់ ខណៈពេលដែលសាលារៀនត្រូវបានបិទ ឬប្តូរមកបង្រៀនតាមអ៊ីនធឺណេតដោយសារតែជំងឺកូវីដ-១៩”។

ឯកអគ្គរាជទូត Kang បានបន្ថែមថា “អូស្ត្រាលីប្តេជ្ញាពង្រឹងទំនាក់ទំនងផ្នែកអប់រំជាមួយកម្ពុជា ការបរិច្ចាគសៀវភៅនេះជាមធ្យោបាយមួយ ដែលស្ថានទូតអូស្ត្រាលីបន្តចូលរួម ជាមួយសាលារៀននៅកម្ពុជា

ដោយសង្ឃឹមថាពួកគេនឹងអាចបើកដំណើរការឡើងវិញ ក្នុងពេលឆាប់ៗនេះ ក្នុងបរិបទដែលមានសុវត្ថិភាពពីជំងឺកូវីដ”។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា ព្រឹត្តិការណ៍នេះបានជួយបញ្ជាក់ពី សារៈសំខាន់នៃអក្ខរកម្មនៅកម្ពុជា។

សប្តាហ៍សៀវភៅត្រូវបានបង្កើតឡើងនៅប្រទេសអូស្ត្រាលី ក្នុងឆ្នាំ ១៩៤៥ ដើម្បីនាំកុមារ អោយស្រលាញ់សៀវភៅ តាមរយៈសកម្មភាពនានា ដូចជា ការប្រកួតសៀវភៅ ការនិទានរឿង ការអាន និងការស្លៀកពាក់តាមសំលៀកបំពាក់តួអង្គក្នុងសៀវភៅហើយដើរតាមផ្លូវ។

ឯកអគ្គរាជទូត Kang បានថ្លែងអំណរគុណដល់ ឯកឧត្តម បណ្ឌិត សភាចារ្យ ហង់ ជួន ណារ៉ុន សម្រាប់ការគាំទ្រកម្មវិធីនេះ និងជួយសម្រួលដល់ការបរិច្ចាគសៀវភៅដល់ សាលាបឋមសិក្សាព្រះនរោត្តម និងសាលារៀននានាក្នុងប្រទេស។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា “ខណៈពេលដែលវាមានការពិបាក ក្នុងការស្វែងរកវិធីបង្រៀនកុមារនៅតាមផ្ទះ ក្នុងអំឡុងពេលមានជំងឺរាតត្បាតនេះ សប្តាហ៍សៀវភៅរំលឹកយើងថា ការអានអាចជម្រុញបំផុសគំនិតយើង ហើយយើងទាំងអស់គ្នាអាចចំណាយពេលដ៏រីករាយ អានសៀវភៅល្អៗ ជាមួយកូនៗ របស់យើង” ៕

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈ Australian.Embassy.Cambodia@dfat.gov.au